# ការផ្សព្វផ្សាយបច្ចេកទេសលើផលិតកម្មស្រូវពូជថ្មី ចំប៉ីស ៧០ របស់ សហគមន៍ស្មើកសិករ នៅភូមិ កំពង់សំបួរ ឃុំស្យា ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់



សហគមន៍កសិកម្មស្មើកសិករ ភូមិកំពង់សំបួរ ឃុំស្យា ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ព្រមព្រៀងផលិត ជាមួយ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តដោយ កសិករ ឈ្មោះ ផា សុគន្ធ លើពូជគ្រាប់ចំប៉ីស ៧០ ចំនួន ១០គីឡូ អនុវត្តលើផ្ទៃដី៣០អា ដោយប្រើប្រាស់ភ្ជួររាស់ដី២ដង និងបច្ចេកទេសស្ទូងសំណាប២-៣ ដើម ចន្លោះគុម្ព(២,៥x៣សម)ក្រោយពេលសាបរយៈពេល១៦ថ្ងៃ ហើយនិងប្រើប្រាស់រយៈពេលសរុប១០០ថ្ងៃតែ



ប៉ុណ្ណោះ។ ការប្រើប្រាស់ដី៣ដំណាក់កាលៈដំណាក់កាលទី១ ប្រើទ្រាប់បាតមុនពេលស្ទូងប្រើជីDAP ចំនួន២០គ.ក្រ បន្ទាប់មកដំណាលកាលទី២បែកគុម្ព ប្រើជីសរីរាង្គធម្មជាតិ ៤បាវស្មើនិង១០០គ.ក្រនិងដំណាក់កាលទី៣ ពេលកកើតកួរប្រើជីបំប៉នលាយបញ្ចូលគ្នា ជីDAP ជីអ៊ុយរ៉េ ជីកាលីសរុប៥៥គ.ក្រ)។ ចំពោះបញ្ហាកើតកន្លងលើស្រូវបាន បាញ់ថ្នាំចំនួន០៣ដង(លើកទី១ ថ្នាំបាញ់ស្មៅនៅពេលរាំង និងអត់ទឹកដាក់លើកទី ២ និងទី៣ បាញ់ថ្នាំដង្កូវលោយនិង



ការពារជំងឺផ្សេងៗ។ តាមរយៈការស្ទង់ទិន្នផលជាបឋម ៤,៨តោន/១ហិកតា។ ក្រោយពេលច្រូតកាត់ទទួលបាន បរិមាណផលស្រូវជាក់ស្តែងសរុបចំនួន១.២២៥គ.ក្រ និងបានលក់ជាស្រូវសើម) ចំនួន៤៨៥គ.ក្រ ដោយក្នុង១គ.ក្រតំលៃ១.៥០០រៀលទៅឱ្យសហគមន៍ស្រែស្អុក ចំនួន ៤៣០គ.ក្រ និងកសិករនៅឃុំអន្លង់វិលចំនួន ៥៥គ.ក្រ សម្រាប់យកទៅផលិតពូជបន្តនៅរដូវក្រោយ។

*រៀបចំនិងចងក្រងព័ត៌មានដោយ៖ ការិយាល័យផ្សព្វផ្សាយកសិកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

កសិករជា សុគន្ធ បានរៀបចំរក្សាទុកជាពូជមួយចំនួនសម្រាប់ធ្វើឆ្នាំក្រោយ សល់ប៉ុន្មានលក់បន្ថែមទៀត ដើម្បីដោះស្រាយការចំណាយលើការងារដាំដុះកន្លងមក។ ចំពោះបញ្ហាកើតកន្លងលើស្រូវ ដូចជាដង្កូវស៊ីរូងដើមបានប្រើថ្នាំបាញ់២ដង(ដោយលាយថ្នាំដង្កូវ និងការពារជំងឺផ្សេងៗ)។

ក្នុងឱកាសនេះដែរ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តពោធិ៍សាត់ សហការជាមួយ ក្រុមហ៊ុនជីសរីរាង្គធម្មជាតិ សុចិត្រា ត្រេឌីង ឯ.ក បានសហការផ្សព្វផ្សាយបច្ចេកទេស លើផលិតកម្មស្រូវពូជចំប៉ីស៧០ និងពន្យល់ពីការប្រើប្រាស់ជី និងសារៈប្រយោជន៍ ដល់អ្នកចូលរួមមកពី សហគមន៍កសិកម្មចំនួន០៣និងសមាជិកដទៃទៀតនិងការជំរុញការសាយភាពប្រភេទពូជស្រូវថ្មី ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្តល់មកមន្ទីរសាកល្បងផលិតឱ្យបានទូលំទូលាយបន្ថែមទៀត។

ជាក់ស្តែងតាមការសង្កេត អ្នកចូលរួមទាំងអស់ទទួលស្គាល់ថាពូជជាពូជសុទ្ធ មិនប្រកាន់ រដូវអាចធ្វើបានច្រើនដងក្នុង១ឆ្នាំ ទិន្នផលខ្ពស់ ប៉ុន្តែទាមទារពេលវេលា សម្រាប់ពិសោធន៍សាកល្បងបន្ថែមទៀត ដើម្បីប្រើប្រាស់ពូជចំប៉ីស ៧០ ជំនួសប្រភេទពូជស្រូវរយៈពេលខ្លីផ្សេងៗទៀត។

លោក ហៃ ធូរ៉ា ប្រធានមន្ទីរបានជំរុញឱ្យកសិករ និងសហគមន៍យកចិត្តទុកដាក់ លើការងារបន្សុទ្ធពូជ ធ្វើយ៉ាងណា ឱ្យទទួលបានពូជសុទ្ធល្អ និងមានតំលៃទីផ្សារខ្ពស់។ម្យ៉ាងទៀត លោកប្រធានបានបញ្ជាក់បន្ថែម ពូជចំប៉ីស៧០ ជាពូជគ្រឹះ ដូច្នេះពូជស្រូវដែលប្រមូលផលថ្ងៃនេះក្លាយជាពូជសុទ្ធអនុញ្ញាតិ ហើយបើកសិករទិញ យកទៅប្រើប្រាស់ សូមជួយណែនាំ ពីបច្ចេកទេសផលិតកម្មស្រូវពូជបន្ថែម ដើម្បីឱ្យកសិករមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការធ្វើស្រែផលិតពូជសម្រាប់លក់បន្ត ទៅឱ្យអ្នកផលិតជាស្រូវចំណីបន្តទៀត។

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំផែនការសាកល្បង ដោយប្រើប្រាស់ពូជស្រូវស្រាល មិនប្រកាន់រដូវ ២ ឬ៣ ប្រភេទផ្សេងៗទៀត ជាមួយពូជចំប៉ីស ៧០ ដើម្បីធ្វើការប្រៀបធៀបលើចំណុច ដូចជា៖ភាពធន់និងការប្រែប្រួលអាកាសធាតុ ការលូតលាស់ ជំងឺនិង សត្វល្អិតបំផ្លាញ ទិន្នផល និងបរិមាណផលទទួលបាន តំលៃស្រូវ និងជាពិសេស តម្រូវការទីផ្សារ ស្រូវ-អង្ករ បច្ចុប្បន្ន។

*រៀបចំនិងចងក្រងព័ត៌មានដោយ៖ ការិយាល័យផ្សព្វផ្សាយកសិកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*